ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ០៧៤/១៦ គ.ជ.ប

# កំណត់ហេតុកិច្ចប្រជុំ
# ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែមិថុនា ថ្ងៃទីប្រាំពីរ វេលាម៉ោងប្រាំបីនិងសែសិបនាទីព្រឹក នៅសណ្ឋាគារអ៊ីមភើរៀល មានបើកកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។**

សមាសភាពចូលរួមក្នុងកិច្ចប្រជុំរួមមានតំណាងក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច ក្រសួងការងារ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អាវុធហត្ថផ្ទៃប្រទេស អង្គការ WI, Cambodia ACTs, UN-ACT, World Vision, TdH-NL, GVC, CCPCR, LSWC និង PHD ។

គោលបំណងនៃកិច្ចប្រជុំគឺ រៀបចំមេរៀន ជ្រើសរើសគ្រូបង្រៀន និងសិក្ខាកាម និងធ្វើផែនការសម្រាប់ការអនុវត្តន៍ ដើម្បីធ្វើយ៉ាងណាឲ្យវគ្គបណ្តុះបណ្តាលចាប់ផ្តើម ដំណើរការ និងបញ្ចប់ទៅដោយរលូន និងទទួលបានលទ្ធផលល្អប្រសើរទៅតាមទិសដៅ និងគោលបំណងដែលបានកំណត់ ជាពិសេសធ្វើយ៉ាងណាឲ្យសិក្ខាកាមដែលបានបណ្តុះបណ្តាលហើយអាចយកទៅអនុវត្តប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។

**បន្ទាប់ពីបានពិភាក្សាយ៉ាងផុលផុស និងដោយយកចិត្តទុកដាក់ អង្គប្រជុំបានលទ្ធផលដូចខាងក្រោម៖**

**១. មតិយោបល់ចូលរួមសម្រាប់ការរៀបចំមេរៀន និងដំណើរការនៃការបណ្តុះបណ្តាល ដែលត្រូវការពិភាក្សា និងពិចារណា ៖**

- ត្រូវគិតឲ្យបានច្បាស់អំពីផែនការ ត្រូវការគ្រូប៉ុន្មាននាក់? សិក្ខាកាមប៉ុន្មាននាក់? បង្រៀនប៉ុន្មានវគ្គ? រយៈពេលប៉ុន្មាន? មានទិសដៅ និងចង់បានលទ្ធផលបែបណា?
- មេរៀននីមួយៗត្រូវមានគោលដៅ ថាតើចង់បានអ្វី ប្រើរយៈពេលប៉ុន្មាន មានវិធីសាស្ត្រអ្វីខ្លះ និងគួរតែមាន Trainer Guide Book សម្រាប់ជួយពេលមានការភ្លេចភ្លាំង ។
- គួរបែងចែកមេរៀនតាមកម្រិត មេរៀនសម្រាប់ការអនុវត្តគឺកម្រិតអ្នកប្រតិបត្តិ និងអាជ្ញាធរពាក់ព័ន្ធ មេរៀនគន្លឹះសម្រាប់នគរបាល និងមន្ត្រីសង្គមកិច្ច ។

- រៀបចំមេរៀនហើយត្រូវបង្រៀនសាកល្បង ដែលពេលនោះត្រូវមានទិន្នន័យ និងឯកសារជំនួយការបណ្តុះបណ្តាលឲ្យហើយស្រេច (រៀបចំមេរៀនភ្ជាប់ជាមួយទិន្នន័យ និងឯកសារជំនួយទៅតាមវិធីសាស្ត្រនីមួយៗ) ។
- បង្រៀនរួចត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ ។
- រៀបចំកូដជនរងគ្រោះ ដើម្បីកុំឲ្យទិន្នន័យជាន់គ្នា ។
- គួរមានប្រើវិធីសាស្ត្រសំនួរ-ចម្លើយ និងតើត្រូវប្រើឧបករណ៍សម្ភារៈអ្វីខ្លះនៅក្នុងការបង្រៀន ។
- ក្រុមបង្រៀនគួរចែកជា ២ក្រុម ដើម្បីឲ្យមានភាពងាយស្រួល និងរហ័ស ។
- គួរបង្កើតជាល្បែងយល់ដឹង ឬវិធីសាស្ត្រដែលអាចឲ្យសិក្ខាកាមយល់ច្បាស់អំពីប្រធានបទ ដូចជាការសិក្សាករណី ឬវីដេអូដែលសមស្របនឹងការបណ្តុះបណ្តាល ។
- ត្រូវពិភាក្សាឲ្យបានលម្អិតថានរណាជាអ្នកកំណត់អត្តសញ្ញាណពិតប្រាកដ ។
- អ្វីដែលបានធ្វើហើយ យើងយកមកពិនិត្យ ខ្វះអីត្រូវថែម មិនត្រូវធ្វើឡើងវិញ ។

២. ព័ត៌មាន និងបទពិសោធន៍ពាក់ព័ន្ធ៖

- វិធីសាស្ត្រសម្ភាសន៍មាននៅក្នុងសៀវភៅគ្រប់គ្រាន់ហើយ អង្គការពាក់ព័ន្ធក៏បានធ្វើហើយ ដែលការសម្ភាសន៍ប្រហាក់ប្រហែលគ្នា គួរយកវិធីសាស្ត្ររបស់ គ.ជ.ប.ជ ជាគំរូ បើមានអ្វីត្រូវបន្ថែមគួរបន្ថែមក្រោយ ។ (ដោយឯកឧត្តម ឧ.ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស)
- បញ្ហាទិន្នន័យ ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៅមានចន្លោះប្រហោងក្នុងការគ្រប់គ្រង់ទិន្នន័យសម្ភាសន៍ជនរងគ្រោះ តែនាយកដ្ឋានមានគម្រោងរៀបចំទិន្នន័យតាមសៀវភៅណែនាំ ដែលនឹងអាចគ្រប់គ្រងទិន្នន័យបានជូន គ.ជ.ប.ជ ។ (ដោយឯកឧត្តម ឧ.ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស)
- សៀវភៅកំណត់អត្តសញ្ញាណដែលរៀបចំដោយAAPTIP និងក្រសួងយុត្តិធម៌ បានដាក់នៅក្នុងបណ្ឌិត្យសភានគរបាលកម្ពុជា ដែលបណ្ឌិត្យសភា និងនាយកដ្ឋានប្រឆាំងការជួញដូរ បានបណ្តុះបណ្តាលអំពីការកំណត់អត្តសញ្ញាណដល់នគរបាលបានជាច្រើនផងដែរ ។ (ដោយឯកឧត្តម ឧ.ទោ យឹម វិរៈ អគ្គលេខាធិការរង គ.ជ.ប.ជ)
- កន្លងមក ពេលជនរងគ្រោះប្តឹងទៅអង្គការ អង្គការបញ្ជូនទៅនគរបាល នគរបាលកំណត់អត្តសញ្ញាណជនរងគ្រោះរួចបញ្ជូនទៅមន្ទីរសង្គមកិច្ច មន្ទីរសង្គមកិច្ចបញ្ជូនបន្តទៅអង្គការមានសេវា តែត្រូវគិតអំពីនីតិវិធី ។ (ដោយឧត្តមសេនីយ៍ទោ ជីវ ផល្លី អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស)

៣. អនុសាសន៍របស់ លោកជំទាវអនុប្រធានអចិន្ត្រៃយ៍៖

- អ្នកដែលអនុវត្តគោលការណ៍ណែនាំ គឺត្រូវតែជាអ្នកដែលមានភារកិច្ចក្នុងការងារនេះ ហើយអ្នកអនុវត្តទាំងនោះនឹងត្រូវទទួលការបណ្តុះបណ្តាលនេះ ។
- មេរៀនយកចំណុចអ្វីខ្លះពីក្នុងសៀវភៅ ត្រូវពិនិត្យខ្លឹមសារនីមួយៗឲ្យបានត្រឹមត្រូវ និងត្រូវយល់ឲ្យបានច្បាស់ ។
- មេរៀនខ្លះអាចនិយាយមុន គឺមិនតម្រូវឲ្យទៅតាមលំដាប់លំដោយទេ ។
- មន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ត្រូវស្រាវជ្រាវប្រមូលទិន្នន័យអំពីសេវានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។
- ត្រូវដឹង និងយល់ឲ្យបានច្បាស់អំពីជំនាញនីមួយៗ ថាតើការប្រគល់និងបញ្ជូនពីកន្លែងមួយទៅកន្លែងមួយមានបែបបទ និងនីតិវិធីអ្វីខ្លះ ដែលមានជារបាយការណ៍ ឬកំណត់ហេតុជាដើម ។

- មេរៀនត្រូវរៀបចំឲ្យមាន Methodology ថាតើចាប់ផ្ដើមយ៉ាងម៉េច បញ្ចប់យ៉ាងម៉េច ដើម្បីទៅដល់គោលដៅដែលបានកំណត់ គឺថាពេលរៀនចប់អាចធ្វើការកើត ។
- ត្រូវការកម្រិតបង្រៀន TOT គឺរៀនហើយយល់ដឹងខ្លួនឯងអាចទៅបង្រៀនបន្តបាន ។
- ឯកភាពឲ្យមាន Trainer Guide Book ។
- ក្នុងតំណាក់កាលនេះយើងយកជនរងគ្រោះជាមូលដ្ឋានសម្រាប់ការបង្ការទប់ស្កាត់ និងការផ្ដន្ទាទោស ព្រោះជនរងគ្រោះជាសាក្សីជាក់ស្ដែង ។
- ត្រូវរៀបចំកិច្ចតែងការបង្រៀន និងបែងចែកក្រុមរៀបចំមេរៀនឲ្យបានឆាប់រហ័ស ។
- ត្រូវយកមេរៀននីមួយៗទៅបំបែកបន្តទៀត ។

**ជាទីបញ្ចប់ អង្គប្រជុំបានឯកភាពសម្រេចចំណុចសំខាន់ៗដូចខាងក្រោម ៖**

**១. មេរៀន ៖**

ក្រុមការងារបានរៀបចំគ្រោងមេរៀនរួម និងបានធ្វើបទបង្ហាញនៅក្នុងអង្គប្រជុំ តែក្រុមនីមួយៗត្រូវបែងចែកក្រុមរៀងខ្លួនដើម្បីរៀបចំមេរៀនរបស់ខ្លួនបន្ត ពេលរៀបចំមេរៀនរួចត្រូវប្រមូលផ្ដុំគ្នាវិញ ។

**២. គ្រូបង្រៀន ៖**

គ្រូបង្រៀនជាបង្គោល និងស្នើសុំការចូលរួមពី៖

- អគ្គស្នងការដ្ឋាននគរបាលជាតិ ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ០២រូប
- ក្រសួងសង្គមកិច្ច ៖ ក្រសួង ០១រូប និងមន្ទីរ ០១រូប
- ក្រសួងការងារ ៖ (key speaker) ០១រូប
- ក្រសួងយុត្តិធម៌ ៖ ០១រូប (ឯកឧត្តម សុច សុផាន់ណារ៉ា អគ្គនាយករងព្រហ្មទណ្ឌ)
- ក្រសួងការបរទេស ៖ ០១រូប (បើមាន)
- អង្គការដៃគូ ៖ ០២ ឬ ០៤រូប ដែលពាក់ព័ន្ធនឹងការងារជួយជនរងគ្រោះកន្លងមក ឧទាហរណ៍ IOM, WI, CWCC, UN-ACT ។ល។
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ៖

**៣. គោលដៅបណ្ដុះបណ្ដាល និងសមាសភាពសិក្ខាកាម ៖**

គោលដៅដំបូងសម្រាប់ការបណ្ដុះបណ្ដាលសាកល្បងគឺ **រាជធានីភ្នំពេញ** និងបន្ទាប់មកប៉ោយប៉ែត ។

**សិក្ខាកាមសម្រាប់ការបណ្ដុះបណ្ដាលនៅរាជធានីភ្នំពេញរួមមាន ៖**

- អគ្គស្នងការដ្ឋាននគរបាលជាតិ ៖ នាយកដ្ឋាន
- អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ៖ នាយរងប៉ុស្តិ៍ច្រកទ្វារ និងប្រធានការិយាល័យពាក់ព័ន្ធ
- កងរាជអាវុធហត្ថ ៖ ការិយាល័យប្រឆាំងការជួញដូរមនុស្ស រាជធានីភ្នំពេញ និងផ្ទៃប្រទេស
- ក្រសួងសង្គមកិច្ច ៖ នាយកដ្ឋាន និងមន្ទីរ
- ក្រសួងអប់រំ ៖ តំណាងក្រុមការងារបង្ការទប់ស្កាត់ ០១រូប ប្រធានមន្ទីរអប់រំ ០១រូប
- ក្រសួងយុត្តិធម៌ ៖ តំណាងក្រុមការងារយុត្តិធម៌ ០១រូប ស្ថាប័នអយ្យការ ០១រូប
- ក្រសួងការងារ ៖ តំណាងក្រុមការងារទេសន្តប្រវេសន៍ ០១រូប ប្រធានមន្ទីរការងារ ០១រូប
- ក្រសួងកិច្ចការនារី ៖ គសនក ឬនាយកដ្ឋាន តំណាងក្រុមការងារទំនាក់ទំនងអន្តរជាតិ ០១រូប ប្រធានមន្ទីរកិច្ចការនារី ០១រូប
- លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ៖ ០១រូប

- អាជ្ញាធរ ៖ ខណ្ឌ សង្កាត់ (អ្នកពាក់ព័ន្ធ)
- សុខាភិបាល ៖ ក្រសួង ឬមន្ទីរ
- អ្នកផ្តល់សេវា ៖ អង្គការ Samaritan Purlse, CWCC, AGAP, CCPCR, Hagar, Ratanak, LSCW, សង់គ្រាល់, ការីតាស ,អាជហុក, លីកាដូ និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ IOM និង IJM ។

៤. ផែនការសម្រាប់អនុវត្ត ៖

តារាងផែនការសម្រាប់អនុវត្តត្រូវបានរៀបចំ និងត្រូវបានពិភាក្សាកែសម្រួលនៅក្នុងអង្គប្រជុំរួចរាល់ ដែលមាននៅក្នុង **តារាងឧបសម្ព័ន្ធ** (Implementation Plan year I)។

កិច្ចប្រជុំបានប្រព្រឹត្តទៅយ៉ាងផុលផុស និងបានបញ្ចប់នៅ វេលាម៉ោងដប់ប្រាំមួយ និងសាមសិបនាទីល្ងាច ថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី១៣ខែមិថុនា ឆ្នាំ២០១៦
**អ្នកកត់ត្រា**

ជាំ.រតនៈ

បានឃើញ និង ឯកភាព
ភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦
**អនុប្រធានអចិន្ត្រៃយ៍**

ជូ ប៊ុនអេង

## Implementation Plan year I

| Targets | Activities | Timeline/Date | Responsible | Needed Support |
|---|---|---|---|---|
| Consultation on the preparation of training curriculum<br><br>Identify target groups for the training | Workshop | 7 June | NCCT | |
| | Meeting/Internal Consultation | | | |
| | | | | |
| | (2 : PP and BMC | | | |
| Identifying trainers' team to develop lesson plans<br><br>Develop training plan | Preparation of lesson plans | 7 June | by specialized groups | |
| | | | | |
| | | | | |
| | | | | |
| Compile lesson plans and develop training manual<br><br>Training curriculum | Workshop : Collection of available training material and selection (workshop) | 30 June | NCCT<br>UNACT/LSCW/IOM/WVI<br>Taining team<br>NCCT/WI | |
| | Test with target groups (internal) | 01 July | | |
| | Workshop to finalize training contents and methodology | 02 July | | |
| | TOT | 15-18 July | NCCT | |
| 100 People trained<br>- (Police post, district police, local authorities, CCWC, Gendarmeries,<br>- DoSVY,<br>- Social workers (SP, | Training in Phnom Penh (30ps) With field practice<br><br>(Workshop to review the training tools) | 27-30 July<br><br>31 July | NCCT/WI<br><br>Cam-Acts | Venue/travel cost |
| | Training in BanteayMeanchey | 12-15 August | WI | |

| | | | | |
|---|---|---|---|---|
| CWCC, AGAP, CCPCR, IJM, IOM, Hagar, Ratanak, Friend, LSCW…), | (Poipet) (30psx2) and field practices | | | |
| | Training in Siem Reap | | WI | |
| | | | UNACT | |
| | | | WV | |
| | | | | |
| | | | | |
| (practice) 500 potential victims interviewed to identify TIP victims by trained people | -Selection system to inform NCCT of the victims identified (TELEGRAM? Email? Excel sheet? Monthly report to NCCT?) | Aug-Dec | NCCT | |
| | -Piloting System | Aug-Dec | NCCT | |
| 100% of potential victims identified referred for services | -System to record referral to service providers | Aug-Dec | MoSAVY | |
| 100% of potential victims identified who have willing to give information (complaint) are investigated by Judicial Police. | -System to refer identified victims for further investigation | Aug-Dec | NCCT | |
| | -Police training on interviewing techniques | Aug-Dec | IJM/AAPTIP/ IOM | |
| | | | | |
| Review the identification process | Sharing workshop on the implementation phase to review and improve the process | Dec | NCCT/Dev.partners | |
| Database system developed with coding system | Database prepared | July-Aug | Consultant/WI | Consultancy fee |
| | Database tested | Aug | Consultant/WI | Travel costs |
| | Training on the use of the database | Aug-Sept | Consultant/WI | Venue/travel costs |

# សមាសភាពចូលរួមក្នុងកិច្ចប្រជុំ
# ស្ដីពីការរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីបែបបទ និងនីតិវិធី
# នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស
# ដើម្បីផ្ដល់សេវាសមស្រប
# ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ នៅសណ្ឋាគារ អ៊ីមភើរៀល

| | | | |
|---|---|---|---|
| -លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ | |
| -លោកជំទាវ | សាន្ត អុណ្ណ | រដ្ឋលេខាធិការ | ក្រសួងកិច្ចការនារី |
| -ឯកឧត្តម | ជួប ណារ៉ាត់ | អគ្គនាយក | ក្រសួងការងារ |
| -ឯកឧត្តម | សុច សុផាន់ណារ៉ា | អគ្គនាយករងព្រហ្មទណ្ឌ | ក្រសួងយុត្តិធម៌ |
| -លោកស្រី | កែវ ម៉ាលី | អនុប្រធាននាយកដ្ឋាន | ក្រសួងសង្គមកិច្ច |
| -ឯកឧត្តម ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ | គ.ជ.ប.ជ |
| -ឯកឧត្តម ឧ.ទោ | ខៀវ ចាន់រ៉ា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| -ឯកឧត្តម ឧ.ទោ | ស៊ុន វ៉ូ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| -ឯកឧត្តម ឧ.ទោ | យឹម វិរៈ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| -ឯកឧត្តម ឧ.ទោ | យ៉ែម ច័ន្ទណារុំ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| -លោកជំទាវ ឧ.ទោ | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| -លោកជំទាវ | រ៉ែន សិរីលក្ខិណា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| -វរសេនីយ៍ឯក | កែវ សុវណ្ណារ៉ា | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| -វរសេនីយ៍ឯក | ហាង ជីវ័ន្ត | អនុប្រធានលេខាធិការដ្ឋាន | គ.ជ.ប.ជ |
| -អនុសេនីយ៍ឯក | ស្រី មករា | នាយរងការិយាល័យ | គ.ជ.ប.ជ |
| -អនុសេនីយ៍ឯក | ហ៊ី រតនៈ | នាយរងការិយាល័យ | គ.ជ.ប.ជ |
| -វរសេនីយ៍ឯក | ហែម បូរ៉ា | ជំនួយការអគ្គលេខាធិការ | គ.ជ.ប.ជ |
| -លោក | សាត់ សោភី | មន្ត្រី | គ.ជ.ប.ជ |
| -ឯកឧត្តម ឧ.ឯក | ប៉ុល ភិជេយ្យ | ប្រធាននាយកដ្ឋាន | នា.ដ្ឋានប្រឆាំងការជួញដូរមនុស្ស |
| -ឧត្តមសេនីយ៍ទោ | ជីវ ផល្លី | អនុប្រធាននាយកដ្ឋាន | នា.ដ្ឋានប្រឆាំងការជួញដូរមនុស្ស |
| -ឧត្តមសេនីយ៍ត្រី | គឹម ភាព | អនុប្រធាននាយកដ្ឋាន | នា.ដ្ឋានប្រឆាំងការជួញដូរមនុស្ស |
| -ឯកឧត្តម ឧ.ទោ | ស រដ្ឋា | អគ្គនាយករង | អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| -វរសេនីយ៍ទោ | ជឿន តារា | ជំនួយការអគ្គនាយករង | អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| -លោក | សឿ ដារ៉ា | នាយការិយាល័យ | អាវុធហត្ថផ្ទៃប្រទេស |
| -លោក | វ៉ា បញ្ញា | នាយផ្នែក | អាវុធហត្ថផ្ទៃប្រទេស |
| -លោកស្រី | Sara Pazzano | COP | WI |
| -លោក | អ៊ុន វុទ្ធី | អ្នកឯកទេសផ្នែកសេវា | WI |
| -លោក | ជុំ ផល្លី | ទីប្រឹក្សា | WI |
| -លោក | លឹម សារ៉ែន | FC | WI |
| -លោក | គង់ វិឡា | ប្រធានកម្មវិធី | Cambodia ACTs |

| | | | |
|---|---|---|---|
| -លោក | អ៊ាង សេងអ៊ាវ | SG | Cambodia ACTs |
| -លោក | លឹម ទិត្យ | អ្នកសម្របសម្រួល | UN-ACT |
| -លោកស្រី | ប៉ែន ចិន្តាមុនី | Project Manager | World Vision |
| -លោក | សួន សុភាព | អ្នកគ្រប់គ្រង | TdH-NL |
| -លោក | ឃី យុទ្ធវីរៈ | P.O | GVC |
| -លោក | មាស សម្បត្តិ | Technical Adviser | CCPCR |
| -លោក | មុំ សុខចាន់ | ប្រធានកម្មវិធី | LSWC |
| -លោកស្រី | ថាន់ ផាន់ណា | អនុ MCH | PHD Kg.Thom |